ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King

ក្រសួងរ៉ែ និងថាមពល
Ministry of Mines and Energy
លេខ: ..........✓..........

# សេចក្ដីប្រកាសព័ត៌មាន
## ស្ដីពី
## ការអនុវត្តគម្រោងមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ឆ្នាំ២០២៦

ក្រសួងរ៉ែនិងថាមពល មានកិត្តិយសជម្រាបជូនសាធារណជននិងប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាប អំពីមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាននិងការប្រើប្រាស់មូលនិធិរ៉ែក្នុងការរួមចំណែកអភិវឌ្ឍន៍សហគមន៍មូលដ្ឋានតាមរយៈការស្នើសុំគម្រោងអភិវឌ្ឍពីរដ្ឋបាលឃុំ សង្កាត់ដូចខាងក្រោម៖

១- ក្នុងការធ្វើអាជីវកម្មរ៉ែ ក្រុមហ៊ុន អាជីវករ ទាំងអស់ត្រូវមានកាតព្វកិច្ចបង់ជូនរដ្ឋនូវសួយសាររ៉ែ និងកាតព្វកិច្ចហិរញ្ញវត្ថុផ្សេងទៀត តាមការកំណត់ក្នុងច្បាប់និងលិខិតបទដ្ឋានគតិយុត្តដែលមានជាធរមាន។ បន្ថែមលើកាតព្វកិច្ចនេះ ក្រុមហ៊ុន អាជីវករ ត្រូវបង់នូវមូលនិធិរ៉ែទ្រទ្រង់កិច្ចអភិវឌ្ឍន៍សហគមន៍មូលដ្ឋាន ដែលក្រសួងរ៉ែនិងថាមពលបានបង្កើតឡើងពីឆ្នាំ២០១៥ ក្នុងគោលបំណងរួមចំណែកជួយដល់មូលដ្ឋាន ឃុំ សង្កាត់ក្នុងការអភិវឌ្ឍឃុំ សង្កាត់ ដែលមានការដ្ឋានរ៉ែស្ថិតនៅ។ ថវិកាដែលបង់ចូលមូលនិធិនេះ សមាមាត្រទៅនឹងទំហំផលិតកម្មរ៉ែដែលក្រុមហ៊ុន អាជីវករបានធ្វើអាជីវកម្មរ៉ែ។

២- មូលនិធិរ៉ែ ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ក្នុងតំបន់សហគមន៍មូលដ្ឋានដែលមានការដ្ឋានរ៉ែស្ថិតនៅ និងអាចប្រើប្រាស់បានក្នុងតំបន់ជិតខាងនៃការដ្ឋានរ៉ែនោះ តាមរយៈការស្នើសុំដោយផ្ទាល់ពីរដ្ឋបាលឃុំ សង្កាត់ ដែលមានការដ្ឋានរ៉ែស្ថិតនៅ។

៣- ចាប់ពីឆ្នាំ២០១៥មកដល់ឆ្នាំ២០២៥ ក្រសួងរ៉ែនិងថាមពលបានអនុម័តឱ្យប្រើប្រាស់មូលនិធិលើគម្រោងចំនួន១៤៤ មានថវិកាសរុប ៩ ៧១២ ៨៨០,៤៤ (ប្រាំបួនលាន ប្រាំពីររយដប់ពីរពាន់ ប្រាំបីរយប៉ែតសិប ក្បៀសសែសិបបួន)ដុល្លារអាមេរិក។

បន្ថែមពីនេះ ក្រសួងរ៉ែនិងថាមពលក៏សូមជម្រាបជូនសាធារណជននិងប្រជាពលរដ្ឋទាំងអស់ឱ្យបានជ្រាបថា សម្រាប់ឆ្នាំ២០២៦ ក្រសួងអនុម័តឱ្យប្រើប្រាស់មូលនិធិលើគម្រោងចំនួន៤៨ មានថវិកាសរុប ៥ ៦៩៥ ៥៦៧,២៨ (ប្រាំលាន ប្រាំមួយរយកៅសិបប្រាំពាន់ ប្រាំរយហុកសិបប្រាំពីរ ក្បៀសម្ភៃប្រាំបី) ដុល្លារអាមេរិក តាមបណ្ដាឃុំចំនួន៤៦ ក្នុងខេត្តចំនួន១០ ដូចមានក្នុងតារាងខាងក្រោម៖

ក្រសួងរ៉ែ និងថាមពល



លេខ ១ មហាវិថីព្រះនរោត្តម សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ទូរស័ព្ទ (៨៥៥) ២៣ ២១៩ ៥៧៤
#1, Preah Norodom Blvd, Sangkat Wat Phnom, Khan Daun Penh, Phnom Penh. Tel: (855) 23 219 574 www.mme.gov.kh info@mme.gov.kh

| ល.រ | ឈ្មោះខេត្ត | ចំនួនឃុំដែលទទួលបាន | ចំនួនគម្រោង | ថវិកាមូលនិធិ(ដុល្លារ) | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | តាកែវ | ១ | ១ | ៤០ ៨៦៩,៤៩ | |
| ២ | កំពត | ៩ | ៩ | ៩៥៧ ៤៤០,២១ | |
| ៣ | កណ្ដាល | ៩ | ៩ | ១ ៣៨៥ ៨៧៣,០៧ | |
| ៤ | ព្រៃវែង | ៧ | ៨ | ១ ១០៥ ៨៦០,៣៥ | |
| ៥ | កំពង់ស្ពឺ | ៨ | ៨ | ១ ០៩២ ៤៩៣,០៩ | |
| ៦ | កំពង់ចាម | ៤ | ៤ | ២២៤ ៩៣៩,៣០ | |
| ៧ | កោះកុង | ១ | ១ | ១២០ ០០០,០០ | |
| ៨ | ក្រចេះ | ២ | ៣ | ៣៤៥ ៨៥៣,០០ | |
| ៩ | ព្រះវិហារ | ២ | ២ | ១៣៨ ៥២៩,៧៧ | |
| ១០ | បន្ទាយមានជ័យ | ៣ | ៣ | ២៨៣ ៧០៩,០០ | |
| | **សរុបរួម** | **៤៦** | **៤៨** | **៥ ៦៩៥ ៥៦៧,២៨** | |

៥- បន្ថែមលើការបង់នូវមូលនិធិរ៉ែនេះ ក្រុមហ៊ុន អាជីវករ រ៉ែ បានជួយរួមចំណែកដោយផ្ទាល់ក្នុងការអភិវឌ្ឍមូលដ្ឋាន តាមរយៈការជួយសាងសង់ផ្លូវ សាលារៀន អណ្ដូងទឹក។ល។ នៅក្នុងឃុំ សង្កាត់ ដែលការដ្ឋានរ៉ែបានស្ថិតនៅ។

អាស្រ័យហេតុនេះ សូមសាធារណជននិងប្រជាពលរដ្ឋទាំងអស់ មេត្តាជ្រាបជាព័ត៌មាន។

ថ្ងៃ សុក្រ ១១រោច ខែបឋមាសាឍ ឆ្នាំមមី អដ្ឋស័ក ព.ស.២៥៧០
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៦